# ការកើតពុំគ្រប់លក្ខណៈ

**(Birth Defects)**
**WUML, 2/5/06**

នៅសប្តាហ៍នេះ នាងខ្ញុំសូមជំរាបអំពីការកើតពុំគ្រប់លក្ខណៈ ដោយអធិប្បាយអំពីមូលហេតុ, បញ្ហាទាក់ទងទៅនឹងការទទួលទានបារីនិងសុរា, ការចាត់ចែងវិធីព្យាបាល និងផលប្រយោជន៏នៃការរក្សាគក៏។

មកទល់នឹងពេលបច្ចុប្បន្ន គេពុំទាន់ដឹងច្បាស់អំពីមូលហេតុនៃការកើតពុំគ្រប់លក្ខណៈនេះនៅឡើយទេ។ ជួនកាលទារកស្រាប់តែកើតមកយ៉ាងដូច្នោះតែម្តងក៏មាន គឺពុំមែនមកពីកំហុសរបស់ឪពុកម្តាយឡើយ។ ឪពុកម្តាយជាច្រើនដាក់កំហុសទៅលើខ្លួនឯង ថាមកពីខ្លួនបានជាកូនកើតមកយ៉ាងដូច្នេះ។ បើសិនជាលោកអ្នកមានកូនកើតពុំគ្រប់លក្ខណៈ ជាការមួយសំខាន់ គួរនិយាយជាមួយឪពុកម្តាយដទៃទៀត ដែលមានបញ្ហាដូចគ្នាដែរ។ ជួនកាល យើងអាចពិចារណាអំពី មូលហេតុខ្លះបានបន្ទាប់ពីទារកកើតហើយ។ ជាការមួយសំខាន់គួរដឹងអំពីវិធីខ្លះៗ ដែលត្រូវអនុវត្តដើម្បីឲ្យទារកមានសុខភាពបរិបូរណ៍ទៅអនាគត។ សកម្មភាពខ្លះៗអាចបណ្តាលឲ្យទារកកើតមកពុំគ្រប់លក្ខណៈ។

ការកើតពុំគ្រប់លក្ខណខ្លះ អាចមានការទាក់ទងទៅនឹងម្តាយដែលទទួលទានបារី នៅពេលមានផ្ទៃពោះ។ ស្ត្រីដែលទទួលទានបារីនៅពេលមានផ្ទៃពោះ អាចបណ្តាលឲ្យទារកកើតពុំគ្រប់ខែ, កើតមកតូច, ឬស្លាប់ក្នុងពោះ។ ជួនកាលអាចធ្វើឲ្យកូនស្លាប់ក្នុងចន្លោះអាយុមួយឆ្នាំបាន។ បញ្ហាដទៃទៀតមានដូចជា៖ កញ្ជួតបរបូមាត់ឬចមុះ, កញ្ជត់កណ្តើត, ជើងកែក, ខូចដៃជើង, កើតរោគបេះដូង, សរសៃពោះស្តើងធ្វើ ឲ្យពោះវៀនចេញមកក្រៅ និងគ្មានរន្ធគូថសំរាប់បន្ទោរលាមក។ ដើម្បីជៀសវាងលក្ខណៈទាំងនេះ អ្នកគួរពិភាក្សាជាមួយគ្រូពេទ្យដើម្បីរក មធ្យោបាយឈប់ទទួលទានបារី នៅពេលមានផ្ទៃពោះ ឬនៅពេលមានគំរោងការណ៍ចង់បានកូន។

ការកើតពុំគ្រប់លក្ខណខ្លះ អាចមានការទាក់ទងទៅនឹងម្តាយដែលទទួលទានសុរា នៅពេលមានផ្ទៃពោះ។ លក្ខណៈរោគដែលបណ្តាលមកពីម្តាយទទួលទានសុរានៅពេលមានផ្ទៃពោះ ភាសាអង់គ្លេសហៅថា **Fetal Alcohol Syndrom** ឬ **FAS** អាចបណ្តាលឲ្យទារកកើតមកដោយមានបញ្ហាខួរក្បាលនិងកើតពុំគ្រប់ លក្ខណៈបាន។ ស្ត្រីដែលទទួលទានសុរា នៅពេលមានផ្ទៃពោះ អាចបណ្តាលឲ្យទារកនិងកើតពុំគ្រប់លក្ខណៈ និងមានបញ្ហាសុខភាពទាំងផ្នែករាងកាយនិងផ្នែកផ្លូវចិត្តអស់មួយជីវិត។ រោគដែលបណ្តាល មកពីម្តាយទទួលទានសុរានៅពេលមានផ្ទៃពោះ ដែលភាសាអង់គ្លេសហៅថា **Fetal Alcohol Syndrome** នេះ ធ្វើឲ្យទាររកមានទំរង់មុខពុំប្រក្រតិ, ពុំធំធាត់ដូចក្មេងដទៃ និងមានបញ្ហាសរសៃប្រសាទ។ ក្មេងទាំងនេះ ច្រើនរៀនសូត្រពុំសូវចេះចាំ, ភ្លឹក, ពុំមានលទ្ធភាពអាចដោះស្រាយបញ្ហាផ្សេងៗ, និយាយពុំច្បាស់លាស់, និងថ្លង់។ បញ្ហាសុខភាពនេះធ្វើឲ្យក្មេងមានការពិបាករៀនសូត្រនិងចូលចំណោមគេពុំចុះ ឧស្សាហ៍ដូចជាចេះតែមានរឿងរ៉ាវច្រើនជា

ដើម។ លក្ខណៈនេះពុំអាចកែវិញបានឡើយ គឺបានន័យថាក្មេងត្រូវរស់នៅដោយ មានលក្ខណៈរបៀបនេះ អស់មួយជីវិត។ ប៉ុន្តែ រោគដែលបណ្តាលមកពីម្តាយទទួលទានសុរានៅពេលមានផ្ទៃពោះ ភាសាអង់គ្លេស ហៅថា **Fetal Alcohol Syndrome** នេះអាចការពារបាន 100% បើសិនជាម្តាយ ជៀសវាងទទួលទានសុរា នៅពេលមានផ្ទៃពោះ។

នៅក្នុងសហរដ្ឋមានទារកចំនួន 3% ដែលកើតមកដោយពុំគ្រប់លក្ខណៈ។ ស្ត្រីខ្លះអាចមានទារកកើតមកពុំគ្រប់លក្ខណៈជាងស្ត្រីឯទៀត។ ស្ត្រីដែលមានផ្ទៃពោះក្នុងពេលមានអាយុពី 35 ឆ្នាំ ឡើងលើ អាចមានបញ្ហានេះច្រើនជាងស្ត្រីដែលក្មេងជាងអាយុ 35 ឆ្នាំ។ ទារកច្រើនកើតមកមានលក្ខណៈ ដែលភាសារអង់គ្លេសហៅថា Down Syndrome ។ ស្ត្រីខ្លះអាចមានទារកកើតពុំគ្រប់លក្ខណៈ បើសិនជាគាត់ទទួលទានថ្នាំអ្វីមួយនៅពេលមានផ្ទៃពោះ។ ឯស្ត្រីដែលទទួលទានបារីនិងសុរានៅពេលមានផ្ទៃពោះក៏មានបញ្ហាយ៉ាងដូច្នោះដែរ។ ស្ត្រីខ្លះទៀតដែលមានទារកកើតពុំគ្រប់លក្ខណៈ ពីព្រោះគាត់មានបងប្អូនដែលធ្លាប់មានទារក កើតពុំគ្រប់លក្ខណៈ។ ដើម្បីចង់ដឹងអំពីជម្ងឺតពូជ អ្នកគួរពិភាក្សាជាមួយគ្រូពេទ្យឯកទេសខាង ជម្ងឺតពូជ ហើយសូមសាកសួរគ្រូពេទ្យ បើសិនជាអ្នកទទួលថ្នាំអ្វីមួយ។ ជាពិសេសជៀសវាង ដាច់ខាត កុំទទួលសុរាឬបារី ហើយទទួលទានថ្នាំជាតិវិតាមិន B Folic acid ឲ្យបានរាល់ថ្ងៃ។

បើសិនជាលោកអ្នកមានទារកដែលកើតមកពុំគ្រប់លក្ខណ គ្រូពេទ្យប្រចាំគ្រួសារ ជាអ្នកព្យាបាលជម្ងឺទូទៅរបស់ទារកលោកអ្នក។ គ្រូពេទ្យនោះអាចដឹងអំពីប្រភពជំនួយផ្សេងៗដែលអាចជួយឧបត្ថម្ភដល់គ្រួសារលោកអ្នកបាន។ ជំនួយទាំងនេះមាន ដូចជា៖ ជំនួយសុខភាពសាធារណៈនិងពត៌មានអំពីឱសថផ្សេងៗជាដើម។ គ្រូពេទ្យនោះនឹងចាត់ចែងវិធីព្យាបាលទាំងឡាយដែលក្មេងត្រូវការ។ ឧទាហរណ៍ បើសិនជា កូនកើតពុំគ្រប់លក្ខណទាក់ទងនឹងឆ្អឹង គាត់នឹងបញ្ជូនទៅគ្រូពេទ្យឯកទេសខាងឆ្អឹង; បើសិនជាកូនមានបញ្ហាទាក់ទងនឹងខួរក្បាល និងសសៃប្រសាទ គាត់នឹងបញ្ជូនទៅគ្រូពេទ្យឯកទេសខាងសសៃប្រសាទ។ ជួនកាលគ្រូពេទ្យប្រចាំគ្រួសារអាចបញ្ជូនកូនលោកអ្នកទៅកម្មវិធីជួយឲ្យធ្វើសកម្មភាពបានគ្រាន់បើ។ កម្មវិធី ដែលគ្រូពេទ្យច្រើនបញ្ជូនទៅគឺ គ្រូពេទ្យហាត់ធ្វើចលនា ដើម្បីឲ្យក្មេងមានកម្លាំងមាំមួននិងធ្វើចលនាបាន រឹងមាំ។

ទារកដែលកើតពុំគ្រប់លក្ខណៈ ច្រើនមានបញ្ហាសុខភាពចំរុះ ហើយត្រូវការគ្រូពេទ្យឯកទេសច្រើននាក់។ ដូច្នេះហើយ បានជាគ្រូពេទ្យប្រចាំគ្រួសារត្រូវការបញ្ជូនកូនលោកអ្នកដើម្បីទៅទទួលជំនួយដែលគ្នាត្រូវការ។ ដោយសង្ខេប ទារកដែលកើតមកពុំគ្រប់លក្ខណៈ មានច្រើន ប៉ុន្តែក្នុងពេលបច្ចុប្បន្ននេះ គេនៅតែពុំទាន់ដឹងអំពីមូលហេតុឲ្យបានច្បាស់លាស់ នៅឡើយទេ។ គ្រូពេទ្យប្រចាំគ្រួសារ ជាគ្រូពេទ្យយ៉ាងចំណានម្នាក់ ក្នុងការចាត់ចែងវិធីព្យាបាលកូនរបស់លោកអ្នក។

ដើម្បីរក្សាទារកក្នុងពោះឲ្យមានសុខភាពល្អ អ្នកគួរ៖

- អញ្ជើញទៅពិនិត្យសុខភាពមុនពេលមានផ្ទៃពោះ,

- រៀបចំព្យាបាលជម្ងឺផ្សេងៗសិន មុននឹងចាប់ផ្តើមមានផ្ទៃពោះ។ ជម្ងឺទាំងនេះមាន ដូចជា ការធាត់ហួស, ជម្ងឺទឹកនោមផ្អែម, ជម្ងឺស្កន់ ឬប្រកាច់ជាដើម។
- ទទួលទានថ្នាំវីតាមីន Folic acide នៅពេលមុន និងកំពុងមានផ្ទៃពោះ។
- រក្សាសុខភាពខ្លួនអ្នកដោយ
    - សំរាកឲ្យបានគ្រប់គ្រាន់,
    - ធ្វើការហាត់ប្រាណឲ្យបានល្មម,
    - ទទួលទានចំណីអាហារឲ្យបានត្រឹមត្រូវទៅតាមកំណត់,
    - ជៀសវាងប៉ះពាល់ជាមួយជាតិគីមីផ្សេងៗដែលអាចផ្តល់វិបត្តដល់ទារកក្នុងពោះ,
    - ជៀសវាងទទួលទានសុរា, បារីនិងគ្រឿងញៀនផ្សេងៗ និង
    - ពិភាក្សាជាមួយគ្រូពេទ្យមុននឹងប្រើថ្នាំផ្សេងៗ

បើសិនជាអ្នកចង់មានផ្ទៃពោះឬកំពុងមានផ្ទៃពោះ ការមួយសំខាន់បំផុតដែលអ្នកគួរអនុវត្ត គឺអញ្ជើញទៅជួបជាមួយគ្រូពេទ្យរបស់អ្នក។ ការអញ្ជើញទៅពិនិត្យផ្ទៃពោះ អាចជួយឲ្យគ្រូពេទ្យរហ័សដឹងអំពីលក្ខណៈខុសធម្មតានៃទារកក្នុងពោះ ហើយចាប់ផ្តើមពិនិត្យតាមដាននិងព្យាបាលមុនពេលឆ្លងទន្លេ។ បញ្ហាខ្លះអាចជៀសវាងបានដោយអញ្ជើញទៅពិនិត្យផ្ទៃពោះឲ្យបានទៀងទាត់។

ការកើតពុំគ្រប់លក្ខណៈខ្លះពុំអាចការពាជាមុនបាន ប៉ុន្តែ ស្ត្រីយើងអាចចាត់វិធានការណ៍រក្សាគក៏ឲ្យទារកមានសុខភាពល្អបាន។ ការកើតពុំគ្រប់លក្ខណៈច្រើនកើតឡើងនៅពេលចាប់ផ្តើមមានផ្ទៃពោះជាដំបូង។ ជួនកាលនៅពេលដែលស្ត្រីពុំទាំងទាន់ដឹងថាខ្លួនមានផ្ទៃពោះនៅឡើយ។ សូមមេត្តាចាំជាក់ថា ការមានផ្ទៃពោះក្នុងសហរដ្ឋចំនួនពាក់កណ្តាល គឺកើតឡើងដោយពុំបានស្មានឬគ្រោងទុកជាមុនឡើយ។

ចំពោះពត៌មានបន្ថែម សូមមេត្តាសាកសួរគ្រូពេទ្យប្រចាំកាយរបស់អស់លោក-លោកស្រី។ ឬ នៅមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល ទូរស័ព្ទទៅ៖

| | | |
|---|---|---|
| មណ្ឌលមេត្តាសុខភាព | (978) 441-1700 | សំរាប់ជ្រើសរើសគ្រូពេទ្យប្រចាំគ្រួសារ |
| កម្មវិធីព្យាបាលគ្រឿងញៀន | (978) 937-9448 | សំរាប់បញ្ហាទាក់ទងនឹងសុរានិងគ្រឿងញៀន |
| កម្មវិធីពិនិត្យផ្ទៃពោះ | (978)446-0788 | សំរាប់ការពិនិត្យនិងរក្សាផ្ទៃពោះ |

*អត្ថបទនេះដកស្រង់ជាចំណែកពី ពត៌មាននៃមជ្ឈមណ្ឌលការពារនិងបង្រ្កាបជម្ងឺ នៃក្រសួងសុខភាពនិង មនុស្សធម៌ (Center for Disease Control and Prevention of U.S. Department of Health and Human Services.) ដែលមានអស័យដ្ឋានរបស់វិបសៃ www.cdc.gov ដោយ មណ្ឌលសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។*